# សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨

## ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨

### ទស្សនៈពិសេសនៅពេលទទួលទានអាហារពេលល្ងាចៈ ការទាញប្រយោជន៍អោយបានប្រសើរបំផុតពីធនធានធម្មជាតិនៅកម្ពុជា_ដីធ្លី អចលនទ្រព្យ ការប្រើប្រាស់ដីប្រកបដោយផលិតភាព និងការអភិវឌ្ឍ

### ការប្រើប្រាស់ដីធ្លីឱ្យមានផលិតភាព និងការអភិវឌ្ឍប្រទេសកម្ពុជាៈ បញ្ហាខាងគោលនយោបាយមួយចំនួន

ដោយលោក **Larry Strange** នាយកប្រតិបត្តិ នៃ វបសអ-CDRI

ឯកឧត្តម លោក លោកស្រី និងភ្ញៀវកិត្តិយសជាទីគោរព ។ ខ្ញុំរីករាយណាស់ដោយមានឱកាសលើកមកជំរាបជូននារាត្រីនេះ អំពីការប្រើប្រាស់ដីធ្លីឱ្យមានផលិតភាព និងការអភិវឌ្ឍប្រទេសកម្ពុជា តាមទស្សនៈរបស់វិទ្យាស្ថានស្រាវជ្រាវខាងគោលនយោបាយអភិវឌ្ឍន៍មួយ ដែលយកចិត្តទុកដាក់ពី ការបង្កើតធនធាន និងការកាត់បន្ថយភាពក្រីក្រ ។

ការស្រាវជ្រាវថ្មីៗរបស់ វបសអ-CDRI និងស្ថាប័នមួយចំនួនទៀត បានបង្ហាញច្បាស់ថា ការប្រើប្រាស់ដីឱ្យមានផលិតភាព និងសុវត្ថិភាពនៃការកាន់កាប់ដី ទាំងនៅតំបន់ជនបទ និងទីក្រុង មានសារៈសំខាន់បំផុតសំរាប់ការអភិវឌ្ឍប្រទេសកម្ពុជា និងកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ហើយវាជះឥទ្ធិពលទៅលើ លទ្ធភាពរកចិញ្ចឹមជីវិត លទ្ធភាពទទួលបានឥណទាន ការវិនិយោគនិងធ្វើចំរុះកម្មកសិកម្ម ទីផ្សារដីធ្លី ការកសាងផ្ទះសំបែង ការអភិវឌ្ឍទីក្រុង និង វិនិយោគលើសហគ្រាសធុនតូចនិងមធ្យម (SME) ។ ការសិក្សានាពេលថ្មីៗរបស់ CDRI ពីភាពក្រីក្រ បង្ហាញថា អ្នកក្រកាន់តែពឹងអាស្រ័យខ្លាំងឡើងលើធនធានធម្មជាតិដែលមានដីធ្លី និងទឹកជាមូលដ្ឋានដើម្បីទ្រទ្រង់ជីវភាពដ៏ផុយស្រួយរបស់ខ្លួន ។ ខណៈដែលគ្រួសារធូរធារ និងគ្រួសារដែលឈានឡើង គេមានដីកាន់កាប់ធំៗ និងទទួលបានទិន្នផលនិងប្រាក់ចំណេញច្រើនជាង គ្រួសារក្រីក្រជាច្រើនកាន់តែមិនអាចរកបានចំណេញពីការធ្វើស្រែ ហើយពួកគេក៏ត្រូវលក់ដី និងពឹងផ្អែកលើការលក់ពលកម្ម ។ ការធ្វើវិនិយោគកាន់តែច្រើន និងផ្តោតកាន់តែខ្លាំង លើការបង្កើនផលិតភាពនៃដីកសិកម្មតូចៗ និងការធ្វើចំរុះកម្មមុខដំណាំ ដូចបានសង្កត់ធ្ងន់ក្នុងគោលនយោបាយបច្ចុប្បន្នរបស់រដ្ឋាភិបាលកម្ពុជា នឹងនាំឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

កត្តាធម្មជាតិផ្សេងៗដូចជា ការរាំងស្ងួត និងទឹកជំនន់ ព្រមទាំង ដីមិនសូវមានជីជាតិ និងកង្វះសមត្ថភាពគ្រប់គ្រងទឹក បានធ្វើឱ្យធ្លាក់ចុះផលិតភាពកសិកម្មនៅតំបន់មួយចំនួន ហើយលទ្ធភាពជាប្រពៃណីក្នុងការប្រើប្រាស់ធនធានព្រៃឈើ និងជលផល ក៏កាន់តែទទួលរងសំពាធនៃកំណើនប្រជាជន និងទំនាស់ជាមួយអ្នកឋានៈខ្ពស់ និងក្រុមអ្នកមានអំណាច ដែលមកពីខាងក្រៅតំបន់ជនបទទាំងនោះ ។ ដោយមូលហេតុនេះ នៅតំបន់មួយចំនួនភាពគ្មានដីធ្លីកំពុងកើនឡើង ទាំងដោយការលក់ដោយចេតនា ទាំងដោយការលក់ទាំងបង្ខំចិត្ត ដែលបានបង្កើនវិសមភាពកាន់កាប់ដីធ្លី នៅជនបទ ហើយអ្នកក្រកាន់តែច្រើនត្រូវលក់កំលាំងពលកម្មនៅក្នុងមូលដ្ឋាន រឺធ្វើចំណាកស្រុកទៅកន្លែងផ្សេង ក្នុងប្រទេសកម្ពុជា រឺទៅប្រទេសថៃ រឺ ម៉ាឡេស៊ី ដើម្បីរកការងារធ្វើ ។

ការស្រាវជ្រាវរបស់យើងបានបញ្ជាក់គាំទ្រមតិដែលថា ជោគជ័យដ៏ធំរបស់កម្ពុជាក្នុងការចុះបញ្ជីដីធ្លី បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងក្របខ័ណ្ឌស្ថាប័ននៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចដ៏មានសន្ទុះរបស់កម្ពុជា ។ ប៉ុន្តែការសិក្សាក៏បង្ហាញដែរថា ប័ណ្ណកម្មសិទ្ធិដីតែមួយមុខ មិនគ្រប់គ្រាន់ទេដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងកាត់បន្ថយភាពក្រីក្រ ។ ប័ណ្ណកម្មសិទ្ធិដីធ្លីចាំបាច់ណាស់ ប៉ុន្តែមិនគ្រប់គ្រាន់ទេ ។ សំរាប់តំបន់ជនបទ ប័ណ្ណកម្មសិទ្ធិដី គ្រាន់តែជាសមាសធាតុដ៏សំខាន់មួយនៃអន្តរាគមន៍ជំរុញការអភិវឌ្ឍដែលត្រូវធ្វើជាចាំបាច់ និងដែលត្រូវមានផងដែរនូវ លទ្ធភាពទទួលបានឥណទានមានតំលៃសមរម្យ ចំណេះដឹង និងព័ត៌មានតាមរយៈសេវាផ្សព្វផ្សាយបច្ចេកទេស និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ ។

គោលនយោបាយរបស់ប្រទេសកម្ពុជាសំរាប់គ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ត្រូវបានតាក់តែងឡើងដើម្បីជំរុញការគ្រប់គ្រងប្រកបដោយចីរភាពនូវដីធ្លី និងទឹក ប៉ុន្តែការអនុវត្ត មិនសូវមានការឯកភាពគ្នានៅថ្នាក់មូលដ្ឋាន កំពុងជំរុញការខូចរេចរិលយ៉ាងលឿននូវមូលដ្ឋានធនធានធម្មជាតិ កំណើនភាពគ្មានដីធ្លី ហើយក្នុងករណីខ្លះបានធ្វើឱ្យសហគមន៍មូលដ្ឋានលែងសូវគោរពដល់ស្ថាប័នសាធារណៈមានសមត្ថកិច្ច ។ ម្យ៉ាងទៀតគួរពិនិត្យជាបន្ទាន់ថា តើដីធ្លី និងធនធានធម្មជាតិមានជាប់ទាក់ទងប៉ុណ្ណានឹងទំនាស់ផ្សេងៗ ជាពិសេសនៅពេលមានពួកឋានៈខ្ពស់ រំលោភយកដីធ្លី រឺក្តោបក្តាប់យកធនធាន ហើយតើទំនាស់ទាំងនេះអាចទប់ស្កាត់ រឺគ្រប់គ្រងយ៉ាងណាដើម្បីឱ្យអ្នកក្រទទួលបានដំណោះស្រាយមិនប្រកាន់បក្សពួក និងយុត្តិធម៌ ទាំងនៅក៏រិតភូមិ និង នៅពេលមានអ្នកធូរធារ និងអ្នកមានអំណាចចូលពាក់ព័ន្ធ ។

ការស្រាវជ្រាវរបស់យើងបានបង្ហាញច្បាស់ពី តំរូវការលៃចែកធនធានកាន់តែច្រើន និងកំណត់គោលដៅកាន់តែច្បាស់សំរាប់ធាតុចូលកសិកម្មនិងអភិវឌ្ឍន៍ ដោយមានការពង្រឹងកាន់តែខ្លាំង និងមិនប្រកាន់បក្សពួក នូវការអនុវត្តច្បាប់/បទប្បញ្ញត្តិផ្សេងៗដែលគ្រប់គ្រងការប្រើប្រាស់ និងការត្រួតត្រាលើធនធានធម្មជាតិ រួមទាំងដីធ្លីផង ។ ចំណាត់ការនេះ នឹងកាន់តែមានប្រសិទ្ធភាពក្នុងការបង្កើនផលិតភាពកសិកម្ម កាត់បន្ថយភាពក្រីក្រ និងលើកកំពស់សុខុមាលភាព បើសិនមានកត្តានៅមូលដ្ឋានជួយបំពេញបន្ថែម ដូចជា សុវត្ថិភាពនៃការកាន់កាប់ដី ប្រព័ន្ធធារាសាស្ត្រ សេវាផ្សព្វផ្សាយបច្ចេកទេស និងឥណទានមានតំលៃសមរម្យ ។

បទពិសោធន៍ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍផ្អែកលើកសិកម្មប្រហាក់ប្រហែលគ្នានឹងកម្ពុជា បានបង្ហាញច្បាស់ថា បើសិនគ្មានការប្រើប្រាស់ដីដោយធ្វើចំរុះកម្ម ដោយមានផលិតភាព និងស្មើភាពគ្នាទេនោះ នឹងមានការអភិវឌ្ឍកសិកម្មទន់ខ្សោយ ការធ្វើចំរុះកម្មមានក៏រិត និងផលប្រយោជន៍តិចតួចសំរាប់កសិករតូចតាចភាគច្រើន ។ ប្រទេសមួយចំនួនអាចជួបគ្រោះថ្នាក់ធ្លាក់ចូលក្នុងរបបសក្តិភូមិបែបថ្មី ដែលក្នុងនេះកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លីប្រមូលផ្តុំក្នុងដៃ ពួកឋានៈខ្ពស់មួយចំនួនតូច ហើយក្រុមនេះជាទូទៅក៏តែងរំលោភយកដីធ្លី និងធនធានធម្មជាតិដែរ ។ ក្នុងសេណារីអូបែបនេះ ការអភិវឌ្ឍអាចឡើងដល់ក៏រិតណាមួយ ប៉ុន្តែបន្ទាប់មកវាលែងមានកំណើន ហើយ ជំរើសដើម្បីធ្វើអភិវឌ្ឍន៍ឱ្យកាន់តែមានចីរភាព និងការកាត់បន្ថយភាពក្រីក្រ ក៏មានតិចដែរសំរាប់ពេលអនាគត ។ បើសិនករណីនេះកើតមានឡើង គេពិបាកនឹងកែតំរូវឡើងវិញណាស់ ។ ដូច្នេះកម្ពុជាអាចរៀនសូត្រពីបទពិសោធន៍នៅប្រទេសផ្សេងៗ និងជៀសវាងគ្រោះថ្នាក់នេះ ។

ការផ្តល់ដីសម្បទានសេដ្ឋកិច្ច គឺជាបញ្ហាប្រទាំងប្រទើស និងស្មុគស្មាញនៅប្រទេសកម្ពុជា ដែលចោទសំនួរជាច្រើនពីលក្ខណៈមិនប្រកាន់បក្សពួក និងតម្លាភាព នៅក្នុងដំណើរការផ្តល់សម្បទាន និងការប្រើប្រាស់មានផលិតភាពខាងសេដ្ឋកិច្ច រឺក៏អត់ ។ ការផ្តល់សម្បទានសេដ្ឋកិច្ចសំរាប់ផលដំណាំលក់យកប្រាក់ និងចំការផ្សេងៗ អាចផ្តល់ផលប្រយោជន៍ខាងសេដ្ឋកិច្ចភ្លាមៗក៏ពិតមែន ប៉ុន្តែវាអាចមានឥទ្ធិពលក្នុងរយៈពេលវែងតិចតួចសំរាប់ជួយដល់ផលិតភាពកសិកម្ម ជីវភាពនៅជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ បើសិនគ្រប់គ្រងមិនបានល្អទេ វាអាចនាំឱ្យមានការទិញដីធ្លីសំរាប់លក់យកចំណេញ ការជៀសវាងពន្ធ ការធ្វើរបងព័ទ្ធយកដីធំៗសំរាប់គោលដៅគ្មានផលិតភាព និងការបន្ទុចបង្អាក់ដល់សហគមន៍មូលដ្ឋានក្នុងការធ្វើអភិវឌ្ឍកសិកម្ម និងជនបទដោយខ្លួនឯង ។ ម្យ៉ាងទៀត សម្បទានដីសង្គមកិច្ចអាចក្លាយជាយន្តការមួយដ៏សំខាន់ដើម្បីផ្តល់ដីធ្លីទៅឱ្យអ្នកគ្មានដី ព្រមទាំងជួយផ្តល់ការណែនាំខាងគោលនយោបាយ និងក្របខ័ណ្ឌមួយ សំរាប់កែប្រែដីព្រៃរបស់រដ្ឋ ទៅប្រើប្រាស់ក្នុងកសិកម្ម ។ ទោះយ៉ាងនេះក្តី ការផ្តល់ដីសម្បទានសង្គមកិច្ចក្នុងពេលកន្លងមក អនុវត្តបានយឺតខ្លាំងណាស់ ដូច្នេះត្រូវតែបន្ថែមល្បឿនទៀត ។

មានសំនួរខាងគោលនយោបាយធំៗមួយចំនួន ដែលគួរយកចិត្តទុកដាក់:

១- តើគោលនយោបាយ និងការគ្រប់គ្រងដីធ្លីបែបណា ជា ផ្លូវកណ្តាលដែលប្រទេសកម្ពុជាត្រូវប្រកាន់យកដោយប្រុងប្រយ័ត្ន ដើម្បីជំរុញការប្រើប្រាស់ដីធ្លីឱ្យមានផលិតភាព និងបង្កើតទ្រព្យធន? ម្យ៉ាងទៀតក៏ត្រូវធានាឱ្យមានដីធ្លីនៅជនបទសំរាប់ ការប្រើប្រាស់មានផលិតភាពខាងកសិកម្ម ដែលចាំបាច់បំផុតដើម្បីអនុវត្តគោលដៅនៃការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ ឱ្យជឿនលឿនទៅមុខទៀត ។

២- តើដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានសង្គមកិច្ច អាចគ្រប់គ្រង និងប្រើប្រាស់យ៉ាងណាឱ្យបានកាន់តែប្រសើរ ដើម្បីជួយជំរុញការវិនិយោគផលិតភាពលើដីធ្លី និងផ្តល់ផលប្រយោជន៍ដល់ទាំងអ្នកធូរធារទាំងអ្នកក្រីក្រ? តើត្រូវគ្រប់គ្រងយ៉ាងណាដើម្បីឱ្យមានតម្លាភាព និងគណនេយ្យភាពកាន់តែប្រសើរក្នុងការផ្តល់សម្បទាន ការកំណត់តំបន់ ការកំណត់តំលៃ និងការបង្កើតចំណូលពន្ធ ?

៣- តើរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន អាចជួយលើកទឹកចិត្តយ៉ាងណាដល់ការអភិវឌ្ឍអចលនទ្រព្យ និងការប្រើប្រាស់ដីធ្លី ដែលមានផលចំណេញខាងសេដ្ឋកិច្ច ជួយដោះស្រាយតំរូវការរបស់សហគមន៍ដែលមានទាំងអ្នកធូធារ និងអ្នកក្រ និងគោរពដល់កេរ្តិ៍ដំណែល និងសីលធមិខាងបរិស្ថានរបស់កម្ពុជា?

សូមអរគុណ